ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៥៥/១៨-សេខូណូ អ៊ិនវេសមេន ខេមបូ ហ្វេសិន
កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **យូ សួនទី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ស៊ីន គីមស៊ាន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **គង់ ផល្លៈ**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន សេខូណូ អ៊ិនវេសមេន ខេមបូ ហ្វេសិន**

អាសយដ្ឋាន ៖ ភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៧០ ៥៦៥ ៥០៦ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមប្រជុំមុនសវនាការ ៖

-លោក តាំង ឯក តំណាងក្រុមហ៊ុន

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន សេខូណូ អ៊ិនវេសមេន ខេមបូ ហ្វេសិន**

អាសយដ្ឋាន ៖ ភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៩៨ ៩៦៨ ១៤១ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួមប្រជុំមុនសវនាការ ៖ អវត្តមាន

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

កម្មករនិយោជិត នៅតែទាមទារសុំឱ្យក្រុមហ៊ុនទូទាត់ប្រាក់បំណាច់អតីតភាពការងារសរុបទាំងអស់ ជូនពួកគាត់។ ដោយឡែក ភាគីនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តទៅតាមប្រកាសលេខ ៤៤៣ កប/ប្រក.ខល ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃ ប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ២២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ (អាណត្តិទី១៦)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូក ទី ១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន សេឌូណូ អ៊ិនវេសមេន ខេមបូ ហ្វេសិន លេខ ១១៨៦ ក.ប/អក/វក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងជួបប្រជុំមុនសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ" ។

**កាលបរិច្ឆេទប្រជុំមុនសវនាការ** ៖ ថ្ងៃអង្គារ ៣កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធីៈ**

នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិត នៃក្រុមហ៊ុន សេឌូណូ អ៊ិនវេសមេន ខេមបូ ហ្វេសិន ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការធ្វើកូដកម្មទាមទារសុំឱ្យក្រុមហ៊ុនដោះស្រាយនូវលក្ខខណ្ឌការងារ ចំនួន ៤ ចំណុច ឱ្យបានល្អប្រសើរ។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះ ដល់ទីតាំងក្រុមហ៊ុន និងធ្វើការផ្សះផ្សាវិវាទនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នា ចំនួន ១ ចំណុច លើការទាមទារ ចំនួន ៤ ចំណុច។ ចំណុចមិនសះជា ចំនួន ១ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន សេឌូណូ អ៊ិនវេសមេន ខេមបូ ហ្វេសិន លេខ ១១៨៦ ក.ប/អក/វក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្ដាលត្រូវបានបង្កើតឡើងនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។ នៅមុនពេលក្រុមអាជ្ញាកណ្ដាលត្រូវបានបង្កើតឡើង លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានទទួលលិខិតមួយច្បាប់ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រុមហ៊ុន សេឌូណូ អ៊ិនវេសមេន ខេមបូ ហ្វេសិន ដែលមានកម្មវត្ថុ សំណើសុំចេញសេចក្ដីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន សេឌូណូ អ៊ិនវេសមេន ខេមបូ ហ្វេសិន។ ហេតុនេះ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចេញសេចក្ដីបញ្ជា លេខ ០០៦/១៨ កបអ. ឱ្យផ្អាកជាបន្ទាន់ នូវការធ្វើកូដកម្មរបស់កម្មករនិយោជិតនៃក្រុមហ៊ុន សេឌូណូ អ៊ិនវេសមេន ខេមបូ ហ្វេសិន រហូតដល់នីតិវិធីនៃអាជ្ញាកណ្ដាលត្រូវបានបញ្ចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីព្រឹកថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ តទៅ តាមវេនរបស់ខ្លួន។

បន្ទាប់ពីចេញសេចក្ដីបញ្ជានេះមក នៅរសៀលថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានទទួលដំណឹងពីភាគីនិយោជក និងកម្មករនិយោជិត តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលថា កម្មករនិយោជិតមួយចំនួនចូលធ្វើការវិញហើយ ប៉ុន្តែ មានកម្មករនិយោជិតមួយចំនួនទៀត មិនបានត្រឡប់ចូលធ្វើការតាមសេចក្ដីបញ្ជានោះទេ ហើយនៅតែបន្តធ្វើកូដកម្មដដែល។ ហេតុនេះ នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០១៩ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានកោះអញ្ជើញភាគីនិយោជក តាមរយៈលិខិតលេខ ០១២ កប/អក/វក/លកអ. ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩ និងតំណាងកម្មករនិយោជិត តាមរយៈលិខិត លេខ ០១៣ កប/អក/វក/លកអ. ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩ ដើម្បីមកសាកសួរព័ត៌មានបន្ថែម ក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្ដាល នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។ បន្ថែមពីនេះទៀត លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល ក៏បានធ្វើការទំនាក់ទំនងតាមរយៈទូរសព្ទទៅភាគីនិយោជក និងតំណាងកម្មករនិយោជិត ដែលមានឈ្មោះ មាស ចន្ទា, ពៅ រំដួល និង ប៊ុន សារ៉ាំ ដើម្បីផ្ដល់ព័ត៌មានអំពីកិច្ចប្រជុំនេះផងដែរ។ នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្ដាល ភាគីនិយោជកមានវត្តមាន តាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ប៉ុន្តែ ភាគីតំណាងកម្មករនិយោជិតមិនមានវត្តមានចូលរួមនោះទេ បើទោះបីជាមន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានទាក់ទងតាមទូរសព្ទទៅពួកគេនៅមុនពេលកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្ដាលចាប់ផ្ដើមក៏ដោយ។ កម្មករនិយោជិតឈ្មោះ មាស ចន្ទា ដែលជាអ្នកតំណាងភាគីកម្មករនិយោជិត បានឆ្លើយតបថា គាត់មិនមកចូលរួមកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្ដាលទេ ព្រោះគាត់ជាប់រវល់ណាស់ ហើយមានកម្មករនិយោជិតមួយចំនួនឈប់ធ្វើការអស់ហើយ។

នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្ដាល ភាគីនិយោជកបានលើកឡើងថា រហូតមកដល់បច្ចុប្បន្ននេះ គឺមានកម្មករនិយោជិតចូលធ្វើការវិញហើយ ដោយឡែកមានតែកម្មករនិយោជិតប្រមាណជា ១០០ នាក់ ដែលមិនព្រមចូលធ្វើការតាមការបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល និងដីការក្សាការពាររបស់តុលាការ ពួកគាត់ទាំងនោះគឺបានព្រមទទួលយកប្រាក់បំណាច់ផ្ដាច់កិច្ចសន្យាការងារពីនិយោជករួចហើយ។ ហេតុនេះ ពួកគាត់ក៏លែងជាកម្មករនិយោជិតនៅក្នុងក្រុមហ៊ុនទៀតដែរ។ សរុបមក នៅក្នុងក្រុមហ៊ុនមិនមានកម្មករនិយោជិតធ្វើកូដកម្មបន្តទៀតទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងធ្វើការពិចារណា ដូចខាងក្រោម ៖

ARBITRATION COUNCIL

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន**

## ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិរបស់ឈ្មោះ SHEN QIMING ជាប្រធានក្រុមហ៊ុន សេខូណូ អ៊ិនវែសមេន ខេមបូ ហ្វេសិន ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ សូមប្រគល់សិទ្ធិជូន លោក តាំង ឯក ជាតំណាងក្រុមហ៊ុន។

២- លិខិតចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រុមហ៊ុន សេខូណូ អ៊ិនវែសមេន ខេមបូ ហ្វេសិន គោរពជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំចេញសេចក្តីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន សេខូណូ អ៊ិនវែសមេន ខេមបូ ហ្វេសិន។

៣- ដីកាសម្រេចរក្សាការពារ លេខ ៥១៨ គ១ ដ.រ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ របស់ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ។

៤- កំណត់ហេតុអនុវត្តដីការរក្សាការពាររបស់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ វេលាម៉ោង ១៤ និង ៣០ នាទី រសៀល។

៥- បញ្ជីឈ្មោះកម្មករនិយោជិតបានផ្តិតមេដៃព្រមទទួលយកការទូទាត់ប្រាក់ផ្តាច់កិច្ចសន្យាការងារ ដោយអនុវត្តតាមដីកាសម្រេចរក្សាការពារ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖** គ្មាន

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន សេខូណូ អ៊ិនវែសមេន ខេមបូ ហ្វេសិន លេខ ១១៨៦ ក.ប/អក/វក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន សេខូណូ អ៊ិនវែសមេន ខេមបូ ហ្វេសិន ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតលេខ ៣៤០ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ៥រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ជម្រាបមកលោក-លោកស្រីតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន សេខូណូ អ៊ិនវែសមេន ខេមបូ ហ្វេសិន ស្តីពីការជ្រើសអាជ្ញាកណ្តាល។

២- កំណត់ហេតុស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាល ពីបញ្ជីឈ្មោះអាជ្ញាកណ្តាលស្នើដោយសហជីព/កម្មករនិយោជិត ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

៣- សេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ០០៦/១៨កបអ. ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

៤- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្ដល់ព័ត៌មាន លេខ ០១២ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ១៣ រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩។

៥- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមផ្ដល់ព័ត៌មាន លេខ ០១៣ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ១៣រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩។

**អង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមិនអាចរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទ ដែលចែងនៅក្នុងរបាយការណ៍មិនសះជារបស់នាយកដ្ឋានវិវាទការងារ ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាលទេ ដោយសារភាគីកម្មករនិយោជិត ដែលជាដើមបណ្ដឹងមិនបានមកចូលរួមក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្ដាល។

**ហេតុផលនៃសេចក្ដីសម្រេច ៖**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងត្រូវបន្តនីតិវិធីអាជ្ញាកណ្ដាលដែរ ឬទេ ក្នុងករណីអវត្តមានភាគីកម្មករនិយោជិតដែលជាភាគីដើមបណ្ដឹង?

ប្រការ ១៨ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ចែងថា ៖ *"ក្រុមអាជ្ញាកណ្ដាលត្រូវអញ្ជើញភាគីវិវាទមកបកស្រាយបង្ហាញដោយផ្ទាល់មាត់ នូវការអះអាងរបស់ខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្ដាល និងដាក់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗទៀត ។"* ។

ប្រការ ២០ នៃប្រកាសខាងលើដដែលនេះ ចែងថា ៖ *"...ភាគីវិវាទ...ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានអញ្ជើញឱ្យចូលរួម ។"* ។

ប្រការ ២១ នៃប្រកាសខាងលើដដែលនេះ ចែងថា៖ *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្ដាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្ដាល ដោយចេញសេចក្ដីបង្គាប់ ។"* ។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ប្រសិនបើភាគីណាមួយមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្ដាល ក្រុមប្រឹក្សាអាជ្ញាកណ្ដាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្ដាលដោយចេញសេចក្ដីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្ដាលត្រូវតែបំពេញតាមលក្ខខណ្ឌថាភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្ដាលមុនពេលធ្វើសេចក្ដីសម្រេចរបស់ខ្លួន ។"* ។

យោងតាមប្រការ ១៨ ប្រការ ២០ និងប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ ខាងលើ និងវិធាន ៤.៧ នៃឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ ខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីនៃវិវាទមានកាតព្វកិច្ចត្រូវចូលរួមរាល់កិច្ចប្រជុំទាំងអស់ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញ។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានបកស្រាយដែរថា មានលក្ខខណ្ឌបីដែលត្រូវបំពេញដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់បាន។ *លក្ខខណ្ឌទី១ គឺ ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ លក្ខខណ្ឌទី២ គឺ ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និង លក្ខខណ្ឌទី៣ គឺ ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ៣០/០៥-មូរ៉េ, លេខ ១៦/០៧-ឡូទូសតី, លេខ ២៧/០៧-អ៊ុម និង វ៉េ ៣, លេខ ៩៥/ ០៨-យ៉ុង វ៉ាទី១, លេខ ១៣២/០៨-ជី អេច ជី, លេខ ១៣៨/០៨-ម៉ាលីន, លេខ ១៥១/០៨-វិល សិន, លេខ ០៩/ ០៩-នីមប៊ីសថិចថាយ, លេខ ០១/១០-ខិននីតិច, លេខ ៣០/១០-ក្លូប័ល អាប៉ារែល, លេខ ១៣០/១៣-ហៃន ធើរេន អីរែវីល, លេខ ១៦៧/១៣-ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល និងលេខ ២៧០/១៣-៨ ស្តារ ស្ពតវែរ)* ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗ ខាងលើដែរ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើលក្ខខណ្ឌទាំងបីនេះ ត្រូវបានបំពេញដែរ ឬទេ?

**លក្ខខណ្ឌទី ១- ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ**

លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានកោះអញ្ជើញភាគីតំណាងកម្មករនិយោជិត តាមរយៈលិខិតលេខ ០១៣ កប/អក/វក/លកអ. ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩ និងបានធ្វើការទំនាក់ទំនងតាមរយៈទូរសព្ទទៅភាគីតំណាងកម្មករនិយោជិត ដែលមានឈ្មោះ មាស ចន្ទ, ពៅ វណ្ឌូល និង ប៊ុន សារ៉ា ដែលជាដើមបណ្តឹង ឱ្យមកចូលរួមកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលយ៉ាងត្រឹមត្រូវ នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០១៩ ដោយមានបញ្ជាក់យ៉ាងច្បាស់លាស់ អំពីកាលបរិច្ឆេទនៃកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល ទីកន្លែងនៃកិច្ចប្រជុំមុនសវនាការ ព្រមទាំងលេខទូរសព្ទ សម្រាប់ទំនាក់ទំនងមកក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ ភាគីតំណាងកម្មករនិយោជិត ក៏បានទទួលនូវការអញ្ជើញចូលរួមកិច្ចប្រជុំមុនសវនាការនេះដែរ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីដើមបណ្តឹងពិតជាទទួលបានការអញ្ជើញ និងជូនដំណឹងយ៉ាងត្រឹមត្រូវអំពី កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល។ ហេតុនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី ២- ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា “*ពាក្យបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល*” នៅក្នុងប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ មានន័យថា ភាគីត្រូវតែមាន ១-វត្តមាននៅក្នុងសវនាការ និង ២-ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាលរហូតចប់សព្វគ្រប់។ ដំណើរការអាជ្ញាកណ្តាលមានបួនដំណាក់កាល ដូចជា ៖

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការដល់អង្គសេចក្តី

បន្ថែមលើនេះ ប្រការ ១៩ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា ៖ *"ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬតំណាងដោយមេធាវី ដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ ។"* ។

នៅក្នុងសំណុំរឿងនេះ អ្នកតំណាងភាគីកម្មករនិយោជិត ឬកម្មករនិយោជិតផ្ទាល់ដែលជាភាគីដើមបណ្តឹង មិនបានបង្ហាញវត្តមាននៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលនោះទេ គឺមានន័យថា មិនបានចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលតាមខ្លឹមសារនៃប្រការ ២១ នៃប្រកាសលេខ ០៩៩ ទេ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតមិនបានមកចូលរួមកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលទេ ។ ហេតុនេះ *លក្ខខណ្ឌទី២ ត្រូវបានបំពេញ* ។

**លក្ខខណ្ឌទី ៣- ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

នៅថ្ងៃកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល វេលាម៉ោងប្រហែល ៩ និង ១៦ នាទីព្រឹក មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទាក់ទងតាមរយៈទូរសព្ទទៅតំណាងកម្មករនិយោជិតម្នាក់ឈ្មោះ មាស ចន្ទ ដើម្បីសួរនាំគាត់ថា តើគាត់មកចូលរួមសវនាការអាជ្ញាកណ្តាលដែរ ឬទេ? កម្មករនិយោជិតឈ្មោះ មាស ចន្ទ បានឆ្លើយតបថា គាត់មិនបានមកចូលរួមទេ ព្រោះជាប់រវល់ណាស់ ហើយមានកម្មករនិយោជិតខ្លះក៏ឈប់ធ្វើការហើយដែរ ។ ករណីនេះ អ្នកតំណាងភាគីកម្មករនិយោជិតមិនបានស្នើសុំមកក្រុមប្រឹក្សាអាជ្ញាកណ្តាលដើម្បីលើកពេលកិច្ចប្រជុំមុនសវនាការ ដោយមូលហេតុខាងលើនេះដែរ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតមិនបានផ្តល់ហេតុផលសម្រាប់អវត្តមានរបស់ខ្លួននោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសន្និដ្ឋានថា អ្នកតំណាងភាគីកម្មករនិយោជិតមិនបានផ្តល់មូលហេតុត្រឹមត្រូវ សម្រាប់ការមិនបង្ហាញខ្លួននេះឡើយ ។ ដូចនេះ លក្ខខណ្ឌទី ៣ ត្រូវបានបំពេញ ។

សរុបសេចក្តីមក លក្ខខណ្ឌទាំងបី ដែលមានចែងក្នុងប្រការ ២១ នៃប្រកាសលេខ ០៩៩ ត្រូវបានបំពេញ ។

នៅក្នុងសំណុំរឿងនេះ ភាគីតំណាងកម្មករនិយោជិត គឺជាដើមបណ្តឹង ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កាតព្វកិច្ចរបស់ភាគីដើមបណ្តឹង និងភាគីចុងបណ្តឹងនៃសំណុំរឿងវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺត្រូវមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបកស្រាយបង្ហាញដោយផ្ទាល់មាត់នូវការអះអាងរបស់ខ្លួន ក៏ដូចជាផ្តល់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗ ដែលពាក់ព័ន្ធនឹងចំណុចវិវាទសម្រាប់ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងសម្រេចសេចក្តី ។

ARBITRATION COUNCIL

ជាទូទៅ ដើមបណ្តឹងមានកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាង ដែលពាក់ព័ន្ធនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីការពារបណ្តឹងទាមទាររបស់ខ្លួន។ ចំណែកឯភាគីចុងបណ្តឹងមានកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដែលពាក់ព័ន្ធ នៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីដោះបន្ទុករបស់ខ្លួនពីការទាមទារ ឬការចោទប្រកាន់ពីសំណាក់ដើមបណ្តឹង ដែលកាតព្វកិច្ចនេះ ជាទូទៅ នឹងត្រូវកើតឡើងក្រោយពេលដែលដើមបណ្តឹងបានបំពេញកាតព្វកិច្ចរបស់ខ្លួនជាមុនសិន។

ក្នុងសំណុំរឿងនេះ ដើមបណ្តឹងមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបំពេញនូវកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាង ដើម្បីការពារបណ្តឹងរបស់ខ្លួនទេ។ លើសពីនេះ ភាគីដើមបណ្តឹង ក៏មិនមានមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួននេះដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា ដើមបណ្តឹងបានបោះបង់ចោលការទាមទាររបស់ខ្លួន។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបន្តដំណើរការអាជ្ញាកណ្តាលនោះទេ។

ផ្អែកតាមវិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ និងប្រកាសលេខ ០៩៩ ព្រមទាំងការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ០៥៥/១៨- ក្រុមហ៊ុន សេឌូណូ អ៊ិនវេសមេន ខេមបូ ហ្សេសិន ដោយចេញសេចក្តីបង្គាប់។

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចសេចក្តីដូចតទៅ៖

## សម្រេច

បញ្ចប់ដំណើរការអាជ្ញាកណ្តាលនៃសំណុំរឿងលេខ ០៥៥/១៨-ក្រុមហ៊ុន សេឌូណូ អ៊ិនវេសមេន ខេមបូ ហ្សេសិន។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក**

ឈ្មោះ៖ **យូ សូនធី**

ហត្ថលេខា៖ ----------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត**

ឈ្មោះ៖ **ស៊ឺន គីមស៊ាន**

ហត្ថលេខា៖ ----------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល**

ឈ្មោះ៖ **គង់ ផល្លះ**

ហត្ថលេខា៖ ----------------------------

THE ARBITRATION COUNCIL